រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :

Project WorldReach PWR ™

474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

040KH01A-01

សកម្មភាពរបស់ពួកអ្នកជំនួយ



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

៤0

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ទូលសូមអោយព្រះជាម្ចាស់ជួយអ្នក តាមរយៈការសិក្សានេះអោយអាចណែនាំបណ្តុះបណ្តាលពួកអ្នកជំនួយ នៅក្នុងក្រុមជំនុំអ្នក ឱ្យកាន់តែមានប្រសិទ្ធិភាព ។

គោលដៅ

- ដើម្បីអោយក្រុមជំនុំរបស់អ្នក ជ្រើសរើសពួកអ្នកជំនួយរបស់ខ្លួន ស្របទៅតាមសេចក្តីត្រូវការ ដូចដែលពួកសាវ័កបានធ្វើ ។
- ដើម្បីអោយក្រុមជំនុំរបស់អ្នកបង្ហាត់បង្រៀនអ្នកជំនួយបុរស និង អ្នកជំនួយស្ត្រី អោយអាចបំពេញភារៈកិច្ចរៀងៗខ្លួន ។
- ដើម្បីអោយក្រុមជំនុំរបស់អ្នក ផ្សព្វផ្សាយដំណឹងល្អអំពីព្រះ-គ្រីស្ត តាមរយៈការធ្វើសកម្មភាពដោយសេចក្តីស្រឡាញ់ ។

តើអ្នកជំនួយមានតួនាទីអ្វី ?

ព្រះគម្ពីរកិច្ចការចែងអំពីរយៈពេលដំបូងរបស់ក្រុមជំនុំ ។ នៅក្នុងជំពូក ៦ យើងឃើញពីរបៀប ដែលក្រុមជំនុំដំបូងជ្រើសរើសអ្នកជំនួយ និង ពីមូលហេតុដែលគេត្រូវជ្រើសរើសអ្នកជំនួយទាំងនោះ ។ ក្រុមជំនុំដំបូងរីកចំរើនយ៉ាងឆាប់រហ័សណាស់...

សូមសរសេរឈ្មោះអ្នកជំនួយ និង កិច្ចការក្នុងក្រុមជំនុំរបស់អ្នក ដែលអ្នកជំនួយនោះត្រូវធ្វើ :

ឈ្មោះអ្នកជំនួយ	ភារៈកិច្ច

© Project WorldReach © SEAN

កិច្ចការដែលត្រូវអនុវត្ត

- ប្រាប់ក្រុមជំនុំរបស់អ្នកអំពីតួនាទី និង មុខងាររបស់អ្នកជំនួយបុរស និង ស្ត្រី (កិច្ចការ ៦:១-៧, ១ ធីម៉ូថេ ៣:៨- ១៣) ។
- រកអោយឃើញថា ក្រុមជំនុំ និង សហគមន៍របស់អ្នក មានសេចក្តីត្រូវការអ្វីខ្លះ ។
- តែងតាំងអ្នកជំនួយបុរស និង អ្នកជំនួយស្ត្រី ដើម្បីអោយពួកគេចាត់ចែងកិច្ចការបំរើអ្នកដទៃ ។
- ផ្តល់ការទទួលខុសត្រូវអោយអ្នកជំនួយម្នាក់ៗ និង បង្ហាត់បង្រៀនពួកគេអោយចេះបំពេញភារៈកិច្ចទាំងនោះ ។
- សូមអោយអ្នកជំនួយស្ត្រីផ្តល់ដំបូន្មានដល់ស្ត្រីឯទៀត ។



© Project WorldReach © SEAN

អ្នកជឿខ្លះឈ្លោះប្រកែកគ្នា អំពីការចែកចំណីអាហារជួយដល់ស្ត្រីមេម៉ាយ ។



សូមសរសេរសេចក្តីត្រូវការបន្ទាន់ខ្លះរបស់ក្រុមជំនុំអ្នក ដែលត្រូវអោយអ្នកជំនួយជួយធ្វើ :

© Project WorldReach © SEAN

- អ្នកក្រ (កាឡាទី ៦:១០) ។
- ស្ត្រីមេម៉ាយចាស់ និង ក្មេងកំព្រា (កិច្ចការ ៦:១, ១ ធីម៉ូថេ ៥:៣-១៦, យ៉ាកុប ១:២៧) ។
- ។ល។ ។

នៅក្នុង លូកា ២១:១-៤ តើព្រះយេស៊ូមានបន្ទូលដូចម្តេច អំពីជង្វាយរបស់ស្ត្រីមេម៉ាយក្រនោះ ? ។

_____

_____

តើអ្នកណាដែលត្រូវទទួលខុសត្រូវ ថែរក្សាស្ត្រីមេម៉ាយខ្លាំងជាងគេ ? (១ ធីម៉ូថេ ៥:៤-១៦) ។

_____

តើស្ត្រីមេម៉ាយបែបណា ដែលសក្តិសមអោយក្រុមជំនុំជួយ ? (១ ធីម៉ូថេ ៥:៩-១៦) ។

_____

_____

_____

សាវ័កទាំងដប់ពីរនាក់របស់ព្រះយេស៊ូគ្រីស្ត ពិភាក្សាគ្នាអំពីបញ្ហានេះ ។ តើពួកគេត្រូវធ្វើដូចម្តេច ? ។





អ្នកជំនួយជួយគ្រួគង្វាល ដោយធ្វើអោយក្រុមជំនុំទាំងមូលចូលរួមជួយអ្នកដទៃ ។



ដើម្បីអាចបំពេញកិច្ចការបំរើខាងជួយអ្នកដទៃនេះ យើងដាក់ដង្វាយស្ម័គ្រចិត្តសំរាប់ :

- ឧបត្ថម្ភគ្រីស្តជនអ្នកបំរើ (១ កូរិនថូស ៩:៤-១៤, ១ ធីម៉ូថេ ៥:១៧-១៨) ។
- ជួយពេលមានគ្រោះអាសន្ន ឬ គ្រោះមហន្តរាយ (កិច្ចការ ១១:២៨-២៩) ។
- អ្នកជឿដែលខ្វះខាត នៅក្នុងក្រុមជំនុំផ្សេងទៀត (១ កូរិនថូស ១៦:១-៤) ។

© Project WorldReach © SEAN

- ផ្តល់ជំបូន្មានដល់អ្នកដែលមានបញ្ហា ។
- ថែទាំ និង ជួយអ្នកជំងឺ ស្ត្រីមេម៉ាយ មនុស្សចាស់ជរា និង អ្នកដែលខ្វះខាត ។
- ដាក់ដង្វាយ ដើម្បីជួយឧបត្ថម្ភដល់ការងារក្នុងក្រុមជំនុំ ។

គិតពិចារណាអំពីសេចក្តីត្រូវការរបស់សហគមន៍ ដែលពួកអ្នកជំនួយរបស់អ្នកត្រូវជួយបំពេញ :

យើងត្រូវបង្រៀនពួកគ្រីស្តជនអំពីភារៈកិច្ចរបស់ពួកគេ ស្របទៅតាមព្រះគម្ពីរ គឺត្រូវជួយអ្នកខ្វះខាត (យ៉ាកុប ២:១៤-២៦) ។

តើព្រះជាម្ចាស់នឹងធ្វើដូចម្តេចចំពោះ «អ្នកជឿ» ក្លែងក្លាយដែលមិនជួយអ្នកខ្វះខាត (ម៉ាថាយ ២៥:៣១-៤៦) ? ។

ការស្រឡាញ់ ដោយការប្រព្រឹត្តល្អ ជាសក្ខីភាពបង្ហាញពីជំនឿដ៏ពិត (យ៉ូហាន ១៤:១៥, ១៥:៥-៦) ។ យើងមិនមែនបានសង្គ្រោះ ដោយការប្រព្រឹត្តល្អទេ តែដើម្បីធ្វើការល្អ (អេភេសូ ២:៨-១០) ។

ពួកសាវ័កយល់ព្រមចំពោះគំនិតនេះ ហើយបានតែងតាំងពួកអ្នកជំនួយដំបូងរបស់ក្រុមជំនុំ ។ អ្នកជំនួយទាំងនោះ គឺលោកស្តេផាន លោកភីលីព លោកប្រូគ័រ លោកនីកាន័រ លោកទីម៉ូន លោកប៉ារមេណាស និង លោកនីកូឡាស ។



...ហេតុនេះហើយបានជាក្នុងក្រុមជំនុំ មានកិច្ចការបំរើពីរផ្នែក គឺ ផ្នែកសាវ័ក និង ផ្នែកអ្នកជំនួយ ។ កិច្ចការទាំងពីរផ្នែកនេះ មានប្រយោជន៍ណាស់ ។

ពួកសាវ័កគិតតែពីអធិស្ឋាន ផ្សាយដំណឹងល្អ និង បង្រៀនព្រះបន្ទូល ។



- អោយចេះស្លៀកពាក់សមរម្យ និង តុបតែងខ្លួន ដោយគ្រឿងលំអ ដែលជាទឹកចិត្តស្លូតបូតស្រគត់ស្រគំ (១ ពេត្រុស ៣:៣-៤, ១ ធីម៉ូថេ ២:៩-១០) ។

អ្នកជំនួយស្ត្រីត្រូវលើកទឹកចិត្តស្ត្រីទាំងអស់ អោយ :

- ថែរក្សាព្រះវិហារឱ្យស្អាតជានិច្ច ដាក់ផ្កាតាំង ។ល។ ។
- មើលថែរក្សា និង បង្រៀនកុមារនៅក្នុងពេលថ្វាយបង្គំ ។
- ទទួលរាក់ទាក់គ្រីស្តជនអ្នកបំរើ ដែលជាភ្ញៀវមកពីឆ្ងាយ ។
- ផ្សាយដំណឹងល្អដល់អ្នកជិតខាង ។
- បង្រៀនស្ត្រីអ្នកជិតខាងអោយចេះផ្តល់អាហារដល់កូនៗ អោយបានត្រឹមត្រូវ ថែរក្សាគ្រួសាររបស់ខ្លួន កាត់ដេរ ខោអាវ... ។ល។ ។
- បង្រៀនពួកអ្នកជិតខាងអោយចេះដាំបន្លែ និង ផ្កា ឬ ធ្វើកិច្ចការ ដែលមានប្រយោជន៍ សំរាប់គ្រួសាររបស់ពួកគេ ។
- បង្រៀនមនុស្សធំ ដែលមិនចេះអក្សរ អោយចេះអាន និង ចេះសរសេរ ។

© Project WorldReach © SEAN

យើងនឹងមើលអំពីសេចក្តី ដែលអ្នកចាស់ទុំស្ត្រី និង អ្នកជំនួយស្ត្រី អាចបង្រៀនដល់ស្ត្រីៗ ដែលនៅក្មេង (ទីតុស ២:៣-៥) ។

អ្នកជំនួយស្ត្រីអប់រំស្ត្រីៗដែលនៅក្មេង :

- អោយចេះស្រឡាញ់ស្វាមី និង កូនរបស់ខ្លួន ហើយអោយមានចិត្តធន់ និង មានចរិយាបរិសុទ្ធក្នុងគ្រប់កិច្ចការ ដែលពួកគេធ្វើ (ទីតុស ២:៤-៥) ។
- អោយរៀបការតែជាមួយអ្នកជឿដូចគ្នា (២ កូរិនថូស ៦:១៤-១៨) ។
- អោយបង្ហាញថា ពួកគេជាមនុស្សអាចទុកចិត្តបាន នៅកន្លែងធ្វើការងារ ហើយអោយយកចិត្តទុកដាក់ខ្លាំងខាងការធ្វើអំពើល្អ (ទីតុស ២:៩-១២) ។
- អោយចេះអធិស្ឋាន និង សិក្សាព្រះបន្ទូលព្រះជាម្ចាស់ ហើយឱ្យធ្វើជាគំរូក្នុងការនិយាយស្តី ជំនឿ ការរស់នៅ និង ចិត្តបរិសុទ្ធ (១ ធីម៉ូថេ ៤:១២-១៣) ។

ពួកអ្នកជំនួយគិតតែពីបំពេញសេចក្តីត្រូវការខាងរូបកាយរបស់មនុស្ស ។



«ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ក៏ឮសុសសាយកាន់តែខ្លាំងឡើងៗ ចំនួនសាវ័កនៅក្រុងយេរូសាឡឹម បានកើនឡើងជាច្រើនឥត-គណនា...» ។

(កិច្ចការ ៦:៧)

សព្វថ្ងៃនេះក៏ដោយ ក៏ក្រុមជំនុំត្រូវតែជួយអ្នកដែលខ្វះខាត ទាំងខាងព្រលឹងវិញ្ញាណ ទាំងខាងរូបកាយដែរ ។ ការបែងចែកការងារឱ្យមនុស្សធ្វើ អាចធ្វើឱ្យការងារកាន់តែមានប្រសិទ្ធិភាព ។ ពួកគ្រូគង្វាលត្រូវបំពេញកិច្ចការឃ្វាលរបស់ខ្លួន គឺទៅសួរសុខទុក្ខ បង្រៀន អធិស្ឋាន និង សិក្សាព្រះបន្ទូលព្រះជាម្ចាស់ ។ល។ ។



កិច្ចការបំរើពិសេសរបស់អ្នកជំនួយស្ត្រី

សូមអោយអ្នកជំនួយស្ត្រីបង្រៀនស្ត្រីឯទៀតៗ និង ធ្វើជាគំរូសំរាប់ស្ត្រីៗ ដែលនៅក្មេង ។

តាមរយៈគំរូរបស់គាត់ អ្នកជំនួយស្ត្រីបង្ហាញស្ត្រីឯទៀត ពីរបៀបប្រព្រឹត្តជាមួយមនុស្សឯទៀត ឬ ជាមួយស្វាមីរបស់ពួកគេ ។ អ្នកជំនួយស្ត្រីប្រើព្រះគម្ពីរ ដើម្បីបង្រៀនស្ត្រីឯទៀត ពីភារៈកិច្ចរបស់គ្រួដណ្តឹង ភរិយា ម្តាយ ស្ត្រីដែលធ្វើការងារ ស្ត្រីអ្នកជំនួញ និង ស្ត្រីមេផ្ទះ ។ អ្នកជំនួយស្ត្រីក៏ត្រូវផ្តល់ដំបូន្មានដល់ស្ត្រីៗ ដែលមានបញ្ហាផ្ទាល់ខ្លួនដែរ ។

តើគ្រីស្តជនស្ត្រីដែលចាស់ទុំខាងព្រលឹងវិញ្ញាណណាមួយ នៅក្នុងក្រុមជំនុំរបស់អ្នក ឬ ក្រុមរបស់អ្នក ដែលអាចផ្តល់ដំបូន្មានតាមរយៈព្រះគម្ពីរដល់ស្ត្រីៗ ដែលនៅក្មេង ? ។

© Project WorldReach © SEAN

នាងលីឌីជាមនុស្សទីមួយ ដែលបានទទួលជឿព្រះគ្រីស្ត នៅទ្វីបអឺរ៉ុប ។ គំរូដ៏ល្អរបស់នាងបានធ្វើអោយក្រុមគ្រួសារនាងថ្វាយខ្លួនដែរ ។ ក្រោយពេលដែលនាងបានថ្វាយខ្លួនហើយ នាងចាប់ផ្តើមបំរើព្រះជាម្ចាស់ភ្លាម ដោយទទួលគ្រីស្តទូតអោយស្នាក់នៅផ្ទះនាង (កិច្ចការ ១៦:១៣-១៥) ។

នាងព្រីស៊ីឡាបានទទួលគ្រីស្តជនជាអ្នកបំរើរបស់ព្រះគ្រីស្ត អោយស្នាក់នៅក្នុងផ្ទះនាង ព្រមទាំងពន្យល់ពួកគេអោយកាន់តែយល់ពីមាគ៌ារបស់ព្រះជាម្ចាស់ថែមទៀតផង (កិច្ចការ ១៨:១-៣, ១៨:២៤-២៦) ។ នាងផ្សាយដំណឹងល្អជាមួយលោកប៉ូល និង ក្រុមរបស់គាត់ ។ នាងអោយគេប្រជុំគ្នាថ្វាយបង្គំនៅផ្ទះនាង ហើយនាង និង ប្តីនាងឈ្មោះអគីឡាស ស៊ូប្តូរជីវិតដើម្បីជួយគ្រីស្តជនអ្នកបំរើឯទៀត (រ៉ូម ១៦:៣-៥) ។

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ **ស្ត្រីនៅភូមិស៊ូណែម**បានទុកបន្ទប់មួយរបស់នាង សំរាប់អោយលោកអេលីសេស្នាក់នៅ ពេលគាត់ធ្វើដំណើរកាត់តាមទីនោះ ។ នាងបានសុំអោយប្តីនាងរៀបចំដាក់គ្រែ តុ កៅអី និង ចង្កៀងនៅក្នុងបន្ទប់នោះ ទុកសំរាប់អោយព្យាការីអាចសំរាន្តដោយសុខស្រួល (២ ពង្សាវតារក្សត្រ ៤:៨-១១) ។

ពួកអ្នកជំនួយក៏បំពេញកិច្ចការបំរើរបស់ពួកគេដែរ ។



© Project WorldReach © SEAN

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ពាក្យអ្នកជំនួយ មានន័យថា «អ្នកបំរើតុ» ។ អ្នកជំនួយជួយគ្រូគង្វាល និង បំរើមនុស្សឯទៀតដែរ ។ ក្រុមជំនុំនិមួយៗត្រូវចាត់តាំងអ្នកជំនួយឱ្យធ្វើកិច្ចការតាមត្រូវការ ។



- អ្នកជំនួយស្ត្រីផ្តល់ដំបូន្មានដល់ស្ត្រី និង ចូលរួមទៅសួរសុខទុក្ខតាមផ្ទះ និង ផ្សាយដំណឹងល្អជាមួយអ្នកឯទៀត ។
- យោងទៅតាម ១ ធីម៉ូថេ ៣:១១ តើអ្នកជំនួយស្ត្រី ត្រូវចៀសវាងពីសេចក្តីល្បួងអ្វីខ្លះ ? ។

ឧទាហរណ៍អំពីអ្នកជំនួយស្ត្រី និង ស្ត្រីអ្នកបំរើកិច្ចការឃ្វាល

នាងផេបេជាអ្នកជំនួយស្ត្រី នៅក្នុងក្រុមជំនុំនៅក្រុងកង់ក្រេ ។ គាត់ជួយពួកគ្រីស្តជនជាអ្នកបំរើរបស់ព្រះគ្រីស្ត ហើយយកសំបុត្រមួយ ទៅជូនលោកប៉ូលដែលនៅទីក្រុងរ៉ូម (រ៉ូម ១៦:១-២) ។

នាងឌ័រកាសតែងតែធ្វើអំពើល្អ និង ជួយអ្នកក្រ ដោយដេរខោអាវសំរាប់ចែកអោយពួកគេទៀតផង (កិច្ចការ ៩:៣៦-៣៩) ។



ការជ្រើសរើសអ្នកជំនួយស្ត្រី

ក្រុមជំនុំជ្រើសរើសអ្នកជំនួយស្ត្រី ដើម្បីអោយបំពេញមុខងារដូចអ្នកជំនួយបុរសដែរ ។ ប៉ុន្តែ ប្រហែលជាអ្នកជំនួយស្ត្រី ច្រើនតែត្រូវចូលរួមធ្វើការជួយក្រុមគ្រួសារ និង ស្ត្រីជាង ។ ក្រុមជំនុំត្រូវជ្រើសរើសអ្នកជំនួយស្ត្រីតាមរបៀប ដែលគេជ្រើសរើសអ្នកជំនួយបុរសដែរ ស្របទៅតាមរបៀបរបបរបស់ក្រុមជំនុំអ្នក ។

តម្រូវការតាមព្រះគម្ពីរសំរាប់អ្នកជំនួយស្ត្រី

- អ្នកជំនួយស្ត្រីក៏ត្រូវមានលក្ខណៈចាំបាច់តាមតម្រូវការក្នុងព្រះគម្ពីរ ដូចអ្នកជំនួយបុរសដែរ (១ ធីម៉ូថេ ៣:៨-១៣) ។
- អ្នកជំនួយស្ត្រីត្រូវជួយធ្វើការងាររបស់ក្រុមជំនុំ ដោយបញ្ចេញពលកម្ម ជាពិសេស ចំពោះអ្នកខ្វះខាត (កិច្ចការ ៦:១-៧, ៩:៣៦-៣៩) ។
- អ្នកជំនួយស្ត្រីសហការជាមួយគ្រូគង្វាល និង អ្នកចាស់ទុំរបស់ក្រុមជំនុំ ដើម្បីធ្វើការងារដែលនាងអាចធ្វើបាន (រ៉ូម ១៦:១២, ទីតុស ២:៣-៥) ។



© Project WorldReach © SEAN

ត្រូវយល់អោយច្បាស់ពីការខុសគ្នារវាងអ្នកជំនួយ និង គ្រូគង្វាល :

ក្នុងក្រុមជំនុំរបស់ពួកសាវ័ក ពួកអ្នកជំនួយបំពេញកិច្ចការបំរើ ដែលមិនមែនជាកិច្ចការដឹកនាំក្រុមជំនុំទេ ។ ឧទាហរណ៍ នៅក្នុងកិច្ចការ ៦:១-៧ ក្រុមជំនុំតែងតាំងមនុស្ស ដែលពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ អោយបំពេញភារៈកិច្ចសំខាន់មួយ ។ តើអ្នកជំនួយធ្វើកិច្ចការអ្វីខ្លះ ? ។

ឯគ្រូគង្វាលវិញ ធ្វើអ្វីខ្លះ ? (១ ពេត្រុស ៥:១-៤) ។

- **គ្រូគង្វាល**ធ្វើកិច្ចការឃ្វាល គឺបង្រៀន និង ដឹកនាំ ។
- **អ្នកជំនួយ**ចុះទៅបំរើអ្នកដទៃដោយផ្ទាល់ គឺធ្វើកិច្ចការបំរើដោយបញ្ចេញពលកម្ម ។

តើអ្នកណាត្រូវទទួលខុសត្រូវមុនគេ ក្នុងការជួយឧបត្ថម្ភអ្នកខ្វះខាត ? (ខ ៤, ៨ និង ១៦) ។

តើក្រុមជំនុំត្រូវជួយស្ត្រីមេម៉ាយប្រភេទណា ? (ខ ៥-៦, ៩-១១) ។

តើស្ត្រីមេម៉ាយនៅវ័យក្មេងត្រូវប្រព្រឹត្តដូចម្តេច ? (ខ ១៤-១៥) ។

សូមអាន ២ ថេស្សាឡូនិក ៣:១០-១៥ ។ តើយើងមិនត្រូវជួយអ្នកណា ? ។

© Project WorldReach © SEAN

ក្រុមជំនុំដែលចេះប្រតិបត្តិតាមព្រះជាម្ចាស់ មិនមែនគ្រាន់តែអធិប្បាយប៉ុណ្ណោះទេ គឺត្រូវបង្ហាញសេចក្តីស្រឡាញ់ តាមរយៈការប្រព្រឹត្តផងដែរ (រ៉ូម ១៣:៨-១០, ១ កូរិនថូស ១៣:១) ។ អ្នកជឿដែលចេះប្រតិបត្តិតាមព្រះជាម្ចាស់ ត្រូវប្រព្រឹត្តអំពើល្អចំពោះមនុស្សទាំងអស់ ជាពិសេសចំពោះបងប្អូនរួមជំនឿ (កាឡាទី ៦:១០) ។

តើយើងជាអ្វីសំរាប់លោកីយ៍ ? (ម៉ាថាយ ៥:១៣-១៤) ។

អំ _____ និង ព _____។

អំបិលនាំអោយមានរសជាតិ និង ជួយការពារមិនឱ្យរលួយខូច ។ ពន្លឺបំភ្លឺផ្លូវផង បង្ហាញអ្វីៗដែលលាក់កំបាំងផង ។ យើងត្រូវធ្វើជាអំបិល និង ពន្លឺសំរាប់ក្រុមជំនុំ និង សហគមន៍របស់យើងដែរ ។

តើត្រូវចៀសវាងបញ្ហាអ្វីខ្លះ ពេលជួយអ្នកខ្វះខាត ?

ការជួយខាងសម្ភារៈ អាចធ្វើអោយមនុស្សមានចិត្តលោភលន់ ។ ហេតុនេះហើយបានជាព្រះជាម្ចាស់ប្រទានដំបូន្មាន ស្តីអំពីរបៀបជួយអ្នកខ្វះខាត ។ អ្នកជំនួយត្រូវជួយអ្នកខ្វះខាត ដោយប្រុងប្រយ័ត្នណាស់ ។ សូមអាន ១ ធីម៉ូថេ ៥:៣-១៦ ។

កំណត់ចំណាំ : ការចុះទៅធ្វើការងារបំរើអ្នកដទៃរបស់ក្រុមជំនុំក៏ជាកិច្ចការបំរើខាងព្រលឹងវិញ្ញាណដែរ ។ « ធ្វើកិច្ចការខាងព្រលឹងវិញ្ញាណ » មានន័យថា « ធ្វើដើម្បីព្រះជាម្ចាស់ » ។ ការបំរើមនុស្សខាងរូបកាយ ក៏ត្រូវធ្វើដើម្បីព្រះជាម្ចាស់ដែរ ។



តើពួកអ្នកជំនួយ ជួយពួកសាវ័កដោយរបៀបណា ? (កិច្ចការ ៦:១-៣) ។

តើនាងផេបេ ដែលជាអ្នកជំនួយស្ត្រី បានជួយអ្នកណាខ្លះ ? (រ៉ូម ១៦:១-២) ។

តើនាងឌ័រកាសជួយអ្នកជិតខាង ដោយរបៀបណា ? (កិច្ចការ ៩:៣៦-៣៩) ។

តើក្រុមជំនុំគួរតែងតាំងអ្នកណា អោយធ្វើជាអ្នកជំនួយ ?

អ្នកជំនួយត្រូវជាអ្នកចាស់ទុំខាងព្រលឹងវិញ្ញាណ ដែលពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ (កិច្ចការ ៦:៣) ។ អ្នកដែលត្រូវធ្វើជាអ្នកជំនួយ ត្រូវបង្ហាញអោយគេឃើញថា គាត់ជាមនុស្សមាន

សេចក្តីបង្គាប់ធំបំផុតរបស់ព្រះជាម្ចាស់ គឺត្រូវស្រឡាញ់ព្រះជាម្ចាស់អោយអស់ពីចិត្តគំនិត និង ស្រឡាញ់បងប្អូនឯទៀតអោយបានដូចស្រឡាញ់ខ្លួនឯង (ម៉ាថាយ ២២:៣៧-៤០) ។ សេចក្តីស្រឡាញ់នេះ ជាសេចក្តីស្រឡាញ់តាមអំពើដែលយើងប្រព្រឹត្ត និងតាមសេចក្តីពិត (១ យ៉ូហាន ៣:១៦-១៨) ។ សេចក្តីស្រឡាញ់នេះ នាំអោយយើងបំរើមនុស្ស ដែលមានសេចក្តីត្រូវការផ្សេងៗ (ម៉ាថាយ ២៥:៣១-៤៦, លូកា ១០:២៥-៣៧) ។

ក្រុមជំនុំត្រូវអធិស្ឋាន រួចចាត់តាំងពួកអ្នកជំនួយអោយចាត់ចែងមុខងារបំរើប្រភេទនេះ ។

តើក្រុមជំនុំរបស់អ្នកមានអ្នកជំនួយដែរឬទេ ? ។

តើក្រុមជំនុំរបស់អ្នកជ្រើសរើសអ្នកជំនួយ ដោយរបៀបណា ? ។

តើពួកគេត្រូវបំពេញមុខងារនេះ ក្នុងរយៈពេលប៉ុន្មាន ? ។

© Project WorldReach © SEAN

☐ មកព្រះវិហារមុនពេលថ្វាយបង្គំយូរបន្តិច ដើម្បីបើកបង្ហួច បើកកង្ហារ សំអាត និង ដាក់ផ្កាក្នុងព្រះវិហារ សំរាប់កម្មវិធីថ្វាយបង្គំ ។ល។ ។

☐ ទទួលគ្រីស្តជនអ្នកបំរើដែលជាភ្ញៀវ តាមរបៀបផ្សេងៗ ។

☐ បង្រៀនអំពីការបរិភោគអាហារ ដែលមានជីវជាតិ ឬ ពីអនាម័យ ។

☐ ជួយជនរងគ្រោះដែលជួបប្រទះគ្រោះថ្នាក់ ឬ គ្រោះមហន្តរាយ ។

☐ បង្រៀនយុវជនអោយចេះប្រកបមុខរបរ ឬ វិជ្ជាជីវៈខ្លះ ។

☐ បង្រៀនវិធីកសិកម្ម ដែលធ្វើអោយដំណាំបង្កើតផលផ្លែបានច្រើន ។

☐ បង្រៀនសមាជិកអោយចេះដាំដើមឈើហូបផ្លែ និង បន្លែ ដើម្បីអាចមានចំណីអាហារ ដែលមានជីវជាតិគ្រប់គ្រាន់ ។

☐ បង្រៀនប្តីប្រពន្ធឱ្យស្គាល់ពីភារៈកិច្ចរបស់ខ្លួន ចំពោះគ្រួសារ របស់ខ្លួន ។

សមត្ថភាព និង គុណសម្បត្តិ អាចបំពេញមុខងារជាអ្នកជំនួយជាមុនសិន (១ ធីម៉ូថេ ៣:១០) ។

សូមអាន ១ ធីម៉ូថេ ៣:៨-១៣ អំពីចរិយាមារយាទរបស់អ្នកជំនួយ ។

យោងទៅតាម ខ ៨ តើអ្នកជំនួយត្រូវមានលក្ខណៈពិសេសដូចម្តេច ? ។

_____

_____

ហេរញ្ញិកក៏ជាអ្នកជំនួយដែរ ពីព្រោះហេរញ្ញិកជាអ្នកទុកដាក់ប្រាក់កាស ។ ហេរញ្ញិកជាមនុស្សដែលចេះទទួលខុសត្រូវ ។ ហេរញ្ញិកត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ ជូនគណៈកម្មាធិការក្រុមជំនុំ ជារៀងរាល់ខែ ។

ហេតុអ្វីបានជាមិនត្រូវតែងតាំងអ្នកជឿថ្មីអោយធ្វើជាអ្នកជំនួយ ? (ខ ៩-១០) ។

_____

_____

តើអ្នកជំនួយ ត្រូវមានចរិយាមារយាទយ៉ាងដូចម្តេច ? (ខ ១១) ។

_____

_____

តើគ្រួសាររបស់អ្នកជំនួយ ត្រូវមានសភាពដូចម្តេច ? (ខ ១២-១៣) ។

_____

_____

_____

តើអ្នកជំនួយនៅក្នុងក្រុមជំនុំរបស់អ្នក បានទទួលការបណ្តុះ-បណ្តាល ដោយរបៀបណា ? ។

_____

_____

_____

_____

ឧទាហរណ៍អំពីភារៈកិច្ចរបស់អ្នកជំនួយ និង ផ្នែកដែលគាត់ត្រូវទទួលខុសត្រូវ (គូសសញ្ញានេះ"✓" នៅនឹងកិច្ចការដែលក្រុមជំនុំអ្នកត្រូវធ្វើ) :

☐ ប្រមូលសំលៀកបំពាក់ ចំណីអាហារ ។ល។ សំរាប់ចែកដល់អ្នកដែលខ្វះខាត ។

☐ បង្រៀនអោយគេចេះអានអក្សរ កាត់ដេរខោអាវ ។ល។ ។

☐ ចាត់ចែងគំរោងផ្សេងៗ ដើម្បីជួយសហគមន៍ ។

☐ ចាត់ចែងការសាងសង់ ការជួសជុល ឬ ការសំអាតព្រះវិហារ ។

☐ លក់ព្រះគម្ពីរ និង សៀវភៅចំរៀងសំរាប់ថ្វាយបង្គំ ។

☐ ធ្វើជាហេរញ្ញិក ឬ លេខារបស់ក្រុមជំនុំ ។

☐ ទៅសួរសុខទុក្ខ និង ជួយអ្នកជំងឺ ស្ត្រីមេម៉ាយ និង កូនកំព្រា ។

☐ ទទួលរាក់ទាក់អ្នកដែលមកចូលរួមថ្វាយបង្គំ ។

© Project WorldReach © SEAN



...ស្វាគមន៍ភ្ញៀវដែលមកព្រះវិហារ និង ទៅផ្សារជួយទិញឥវ៉ាន់អោយមនុស្សចាស់ជរា ។ល។ ។

អ្នកជំនួយម្នាក់ៗមានភារៈកិច្ចរៀងៗខ្លួន ។ គេមិនមែនជ្រើសរើសអ្នកជំនួយសំរាប់ឱ្យអ្នកនោះមានបុណ្យសក្តិអ្វីមួយទេ គឺគេជ្រើសរើសគាត់ឱ្យបំពេញ**កិច្ចការបំរើ ដោយបញ្ចេញកំឡាំងពលកម្ម** ។

អ្នកជំនួយចុះទៅធ្វើការងារជាមួយក្រុមរបស់គាត់ ដោយទាក់ទងជាប់ជាមួយគ្រូគង្វាល និង សមាជិកឯទៀត ។ ការសំខាន់ គឺត្រូវណែនាំសមាជិកក្រុមជំនុំម្នាក់ៗ អោយចូលរួមធ្វើកិច្ចការបំរើរបស់ក្រុមជំនុំ ។ តួនាទីរបស់អ្នកជំនួយ គឺរៀបចំ និង ធ្វើកិច្ចការផ្សេងៗ គឺថាអ្នកជំនួយត្រូវចូលរួមធ្វើខ្លួនឯងផង ហើយជំរុញ និង ចាត់តាំងសមាជិកឯទៀតអោយចូលរួមធ្វើផង ។

ភារៈកិច្ចរបស់អ្នកជំនួយ

ពួកអ្នកជំនួយបំរើក្រុមជំនុំ និង សហគមន៍តាមមូលដ្ឋាន ដោយរបៀបផ្សេងៗ ។ ពួកគេបង្ហាញសេចក្តីស្រឡាញ់របស់ព្រះគ្រីស្តចំពោះអ្នកដែលខ្វះខាត ។



© Project WorldReach © SEAN







ទទួលភ្ញៀវ



សំអាតព្រះវិហារ

ហើយការងារច្រើនផ្សេងទៀត សំរាប់អ្នកជំនួយ...



ធ្វើជាហេរញ្ញិករបស់ក្រុមជំនុំ



កាត់ដេរខោអាវសំរាប់ជួយអ្នកខ្វះខាត

អ្នកជំនួយប្រាប់យើងអំពីរបៀបដាំបន្លែ ។ ដូច្នេះ ឆ្នាំនេះ យើងមានចំណីអាហារបរិភោគច្រើនជាងឆ្នាំមុនៗហើយ ។



ពេលបងឃើញទឹកចាប់ផ្តើមពុះ បងត្រូវទុកទឹកនោះឲ្យពុះ ១០នាទី ដើម្បីសំឡាប់មេរោគ និង ពងព្រូន ។



មែនឬ ?

ដោយសារបងៗមានបង្គន់អនាម័យថ្មី បងៗអាចចៀសផុតពីជម្ងឺជាច្រើន ។



អរគុណក្មួយណាស់ ដែលខំជួយជួសជុលផ្ទះអោយអ៊ំព្រោះអ៊ំចាស់ណាស់ហើយ ។



ឥឡូវនេះ ដោយសារពូសុភាពឈឺ ទើបក្រុមជំនុំអោយខ្ញុំយករបស់នេះមកជូនមីង និង កូនៗ ។



ពូរៀនឆាប់ចេះណាស់ ។ ឥឡូវនេះ ពូអាចបង្រៀនអ្នកឯទៀតបានដែរ ។



ឥឡូវ ខ្ញុំចេះអានហើយ ។ ខ្ញុំបានដឹងអ្វីៗច្រើនដោយសារអានសៀវភៅ ! ខ្ញុំនឹងបង្រៀនជុន និង ម៉ុំ ដូចដែលលោកគ្រូបានបង្រៀនខ្ញុំដែរ ។

© Project WorldReach © SEAN